## <u>ការបំពានទីតិវិធី (Abuse of Process)</u>

<u>១</u>. ដំណើរការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ អាចបញ្ចប់ជាស្ថាពរ ក្រោយជនជាប់ចោទត្រូវបានកាត់ទោស ឬក្នុងករណីខ្លះ នីតិវិធីត្រូវបានផ្អាកជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដោយសារមូលដ្ឋានមួយចំនួន ដូចជាការបំពាននីតិវិធី (abuse of process: AC)។ AC ជាការប្រើប្រាស់នីតិវិធីមិនសមស្របជាមួយឆន្ទះមិនត្រឹមត្រូវ។ វាជាការបំពាននីតិវិធី ដោយអាជ្ញាធរមានសមត្ថកិច្ច ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិជនសង្ស័យជាដើម។

<u>២</u>. ទោះបីជាយ៉ាងនេះក្តី ការបំពានត្រូវតែធ្ងន់ធ្ងរ ទើបនាំឲ្យមានការផ្អាកនីតិវិធីជាអចិន្ត្រៃយ៍ (permanent stay of proceeding) ហើយដំណោះស្រាយនេះ គឺជាជម្រើសចុងក្រោយ (last resort)។ វាដូចជាករណី ដែលមន្ត្រីប៉ូលីស បានធ្វើទារុណកម្មធ្ងន់ធ្ងរដល់ជនជាប់ចោទ ដើម្បីយកចម្លើយសារភាព បំពានសិទ្ធិរួចផុតពីអំពើទារុណកម្ម ដែលជាសិទ្ធិដាច់ខាត (absolute rights)។ ការបញ្ចប់នីតិវិធី ផ្អែកទៅតាមការថ្លឹងថ្លែងផលប្រយោជន៍ (balance of interests) ជាពិសេស ក្នុងការចោទប្រកាន់បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ដូចជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលផលវិបាកនៃទង្វើរបស់ជនល្មើស មានវិសាលភាពធំធេង និងធ្ងន់ធ្ងរ។ ជំនួសឲ្យការផ្អាកនីតិវិធី ការកាត់បន្ថយទោសដែលជនសង្ស័យនឹងទទួល ក្នុងករណីរកឃើញថា មានទោស ជាសំណងមួយចំពោះ ការប៉ះពាល់សិទ្ធិសេរីភាព។

<u>៣</u>. ក្នុងសំណុំរឿង *Lubanga Dyiol* នៃ ICC អង្គជំនុំជម្រះទី១ បានសម្រេចបញ្ចប់នីតិវិធីប្រឆាំងគាត់ ដោយសារកំហុសរបស់ រដ្ឋអាជ្ញា ខកខានមិនបានបញ្ចេញភស្តុតាងដោះបន្ទុក (disclosure of exculpatory evidence) ដែលនេះត្រូវបានចាត់ថាបំពាននីតិវិធី។ តុលាការ បានឆ្លើយតបនឹងការបំពាននីតិវិធី ដូចជាការយឺតយ៉ាវរបស់ព្រះរាជអាជ្ញា និងទីពីរ ការរំលោភសិទ្ធិក្នុងដំណើរការនាំខ្លួនជនសង្ស័យ មកមុខតុលាការ ដែលទាមទារឲ្យមានអន្តរាគមន៍ពីតុលាការ ក្នុងខ្លឹមសារដូចខាងក្រោម៖ *តុលាការ មានឆន្ទានុសិទ្ធិ ក្នុងការផ្អាកនីតិវិធីព្រហ្មទណ្ឌ ផ្អែកលើមូលដ្ឋានថា ការបន្តនីតិវិធីទាំងនោះ នឹងជាការបំពាននីតិវិធីរបស់ខ្លួន ដោយសារ (១). វាមិនអាចធ្វើទៅបាន (ដោយសារមូលហេតុយឺតយ៉ាវ) ក្នុងការផ្តល់ការវិនិច្ឆ័យសេចក្តីប្រកបដោយ យុត្តិធម៌ដល់ជនជាប់ចោទ ឬ (២). វាប៉ះទូវខ្លឹមយុត្តិធម៌របស់តុលាការ និងភាពសមស្របត្រូវបានលើកឡើងក្នុងការវិនិច្ឆ័យជនជាប់ចោទ នៅក្នុងស្ថានភាពនៃករណីណាមួយ។*[1]

---

[1] *Prosecutor v. Barayagwiza*, ICTR-97-19-AR72, AC, 3 November, 1999, para.74.

**កំណត់សំគាល់**៖ ក្នុងនីតិវិធីដេញដោលដើម្បីសម្រេចថា ឃុំខ្លួន ឬមិនឃុំខ្លួន ឌុច ក្នុងសំណុំរឿងលេខ ០០១ នៃ អវតក ឌុចបាន អះអាង ថាការឃុំខ្លួនខុសច្បាប់ដោយតុលាការយោធា ជាការបំពាននីតិវិធី ហើយថា អវតក មិនត្រូវបន្តនីតិវិធីប្រឆាំងនឹងគាត់ទេ។ សហចៅក្រមស៊ើបអង្កេត បានចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ដែលក្នុងនោះ បញ្ហាបំពាននីតិវិធី ត្រូវបាន ពិភាក្សាផងដែរ http://www.measboralaws.com/detail/1095 ។ នៅក្នុងដំណាក់សវនាការ ឌុច បានស្នើជាថ្មីឲ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងគាត់ ផ្អែកលើមូលដ្ឋាននេះដែរ។ អង្គជំនុំជម្រះបានពិចារណា និងអះអាងថា នៅពេលរកឃើញ ឌុច មានទោស ចំនួនទោស ក្នុងពន្ធនាគារអាចនឹងត្រូវកាត់បន្ថយ http://www.measboralaws.com/detail/97។

**ឯកសារយោង**៖ Colin Warbrick, *Abuse of Process*, p. 226 and Michel Miraglia, *lubanga Dyilo*, pp.797-799, in Antonio Cassese, the Oxford Companion to International Criminal Justice, 2009។ Ken Oliphant (ed.), the Liability of Public Authorities in Comparative Perspective, 2016, pp. 690, 695.

**Further Reading**: Naqvi, Yasmin Q., Impediments to Exercising Jurisdiction over International Crimes, 2010; Colin Wells, Abuse of Process, A Practical Approach, 2006.